# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

## កិច្ចព្រមព្រៀង ព្យួរកិច្ចសន្យាការងារ

**<u>កិច្ចព្រមព្រៀងនេះធ្វើឡើងរវាង</u>**

ក្រុមហ៊ុន **អេអិមអិម អេឡិចត្រូនិក (ខេមបូឌា) អិលធីឌី** មានអាសយដ្ឋាន៖ តំបន់សេដ្ឋកិច្ចពិសេសមេនហាត ធេន ផ្លូវជាតិលេខ១ ភូមិថ្នាញ សង្កាត់បាទី ក្រុងបាវិត ខេត្តស្វាយរៀង។ ចាប់ពីពេលនេះទៅហៅថា **ភាគី«ក»**

ដែលមានលោក ជា វុទ្ធី ភេទ ប្រុស អាយុ ៣៨ ឆ្នាំ អត្តសញ្ញាណប័ណ្ណលេខ ០១០៥៣៩១០៩
អាសយដ្ឋាន ផ្ទះលេខ ១១១H ផ្លូវ ៩៣ ភូមិ ទូលសង្កែ សង្កាត់ ទូលសង្កែ ខណ្ឌ ឫស្សីកែវ រាជធានី ភ្នំពេញ **ជាតំណាង**។

**<u>និង</u>**

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ ប្រាក់ ចន្ថា ភេទ ស្រី អាយុ ២៨ ឆ្នាំ អត្តសញ្ញាណប័ណ្ណលេខ ០៩០៨៦៦៨៥១
អាសយដ្ឋានផ្ទះលេខ គ្មាន ផ្លូវ លំ ភូមិ ប្រកលាវ សង្កាត់ បាវិត ក្រុង បាវិត ខេត្តស្វាយរៀង។
មុខរបរ កម្មករ ចាប់ពីពេលនេះតទៅហៅថា **ភាគី«ខ»** (តំណាងកម្មករ)។

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ ហាស់ សាបិន ភេទ ស្រី អាយុ ២២ ឆ្នាំ អត្តសញ្ញាណប័ណ្ណលេខ ០៩០៦១៩៦២៤
អាសយដ្ឋានផ្ទះលេខ គ្មាន ផ្លូវ លំ ភូមិ ធ្លក សង្កាត់ ប្រកម្ទេស ក្រុង បាវិត ខេត្តស្វាយរៀង។
មុខរបរ កម្មករ ចាប់ពីពេលនេះតទៅហៅថា **ភាគី«ខ»** (តំណាងកម្មករ)។

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ ឡាត មករា ភេទ ស្រី អាយុ ២០ ឆ្នាំ អត្តសញ្ញាណប័ណ្ណលេខ ០៩០៧៣៣១១២
អាសយដ្ឋានផ្ទះលេខ គ្មាន ផ្លូវ លំ ភូមិ ធ្លក សង្កាត់ សង្ឃ័រ ក្រុង ស្វាយរៀង ខេត្តស្វាយរៀង។
មុខរបរ កម្មករ ចាប់ពីពេលនេះតទៅហៅថា **ភាគី«ខ»** (តំណាងកម្មករ)។

### ភាគីទាំងពីរបានព្រមព្រៀងគ្នាដូចខាងក្រោម៖

**ប្រការ១ ភាគី«ខ»** បានយល់ព្រមទទួលព្យួរកិច្ចសន្យាការងារពី **ភាគី»ក«** ចំនួន៣១ថ្ងៃ គិតចាប់ពីថ្ងៃទី០១ ខែកក្កដា ឆ្នាំ ២០២០ ដល់ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២០ ដោយមូលហេតុក្រុមហ៊ុន ត្រូវបានផ្អាកការកម្មង់ទិញពីអតិថិជនដែលស្ថិតក្នុងប្រទេសកំពុងរងនូវឥទ្ធិពលវីរុស **កូវីដ-១៩** យ៉ាងធ្ងន់ធ្ងរ។

**ប្រការ២ ភាគី«ខ»** បានយល់ព្រមទទួលប្រាក់ឧបត្ថម្ភពី **ភាគី»ក«** ចំនួនទឹកប្រាក់ ៥០ ដុល្លាអាមេរិក ( ហាសិប ដុល្លាអាមេ រិក)។

**ប្រការ៣ ភាគី»ក«** សំណូមពរបើកប្រាក់ឈ្នួលកិច្ចសន្យាការងារអោយ **ភាគី»ខ«** នៅថ្ងៃទី១០ នៃខែបន្ទាប់ ហើយ**ភាគី»ខ«** ក៏បានយល់ព្រមទទួលតាមសំណូមពរខាងលើនេះ ដោយឆ្លងកាត់ការប្រជុំពិភាក្សាជាមួយនឹងបងប្អូនកម្មករទាំងអស់ផងដែរ។

**ប្រការ៤ ភាគីទាំងពីរ** ត្រូវអនុវត្តតាមកិច្ចព្រមព្រៀងនេះ ឲមានប្រសិទ្ធិភាព និងស្មារតីទទួលខុសត្រូវខ្ពស់ ដោយមិនមានចេតនាទុច្ចរិត ឬ គេចវេស ដែលជាមូលហេតុធ្វើឲខាតបង់នូវផលប្រយោជន៍របស់ **ភាគីណាមួយ** បានឡើយ។

**ប្រការ៥** ករណីដែល **ភាគីណាមួយ** មិនអនុវត្តកាតព្វកិច្ចរបស់ខ្លួនទៅតាមកិច្ចព្រមព្រៀងនេះ ឲបានត្រឹមត្រូវ និង ដោយតម្លាភាព ឬ មានចេតនាមិនព្រមអនុវត្តកាតព្វកិច្ចរបស់ខ្លួនទេនោះ **ភាគីម្ខាងទៀត** មានសិទ្ធិចាត់នូវវិធានការទៅតាមផ្លូវច្បាប់ជាធរមាន។

**ប្រការ៦ ភាគីទាំងពីរ** ត្រូវអនុវត្តកាតពញកិច្ច តាមកិច្ចព្រមព្រៀងខាងលើ ឲបានត្រឹមត្រូវ តម្លាភាព ដោយចៀសវាងនូវគំនិតទុច្ចរិតផ្សេងៗ

កិច្ចព្រមព្រៀងនេះធ្វើឡើងដោយពិតប្រាកដ និងដោយសេរី មិនមានការបង្ខិតបង្ខំ ឬគំរាមគំហែងឡើយ គឺធ្វើឡើងដោយ ខ្ញុំបាទ/នាងខ្ញុំ មានសតិស្មារតីគ្រប់គ្រាន់ ហើយបានអាន និងបានស្ដាប់យ៉ាងត្រឹមត្រូវ។

កិច្ចព្រមព្រៀងនេះ មានសុពលភាពអនុវត្តចាប់ពីថ្ងៃដែល ខ្ញុំបាទ/នាងខ្ញុំ បានផ្ដិតមេដៃស្ដាំទទួលយល់ព្រមតទៅ។

ថ្ងៃពុធ ១១កើត ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤
បារិត ថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២០

បានឃើញ និងឯកភាព
តំណាងកម្មករ (**ភាគី«ខ»**)

ប្រាក់ ចន្ថា　　ហាស់ សាបិន　　ឡាតមករា

បានឃើញ និងឯកភាព
តំណាងក្រុមហ៊ុន (**ភាគី«ក»**)

ព្រះរាជាណាចក្រកម្ពុជា
ក្រុមហ៊ុន
AMM ELECTRONIC (CAMBODIA) LTD.
KINGDOM OF CAMBODIA

ជា វុទ្ធី